# កតញ្ញុតាធម៌ *(បទកាគតិ)*

*កតញ្ញូតា មានន័យប្រាប់ថា ជនកតញ្ញូ*
*ត្រូវតែប្រព្រឹត្ត តាមបែបគំរូ ដែលព្រះបរមគ្រូ*
*ប្រាប់ឲ្យតបគុណ ។*

*មាតាបិតា គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ*
*ជនណាក៏ដោយ ដែលគេមានគុណ ក៏ជាស្រែបុណ្យ*
*ដែលគេត្រូវព្រោះ ។*

*បណ្ដុះពូជបុណ្យ ក្នុងស្រែជាគុណ កុំឲ្យមានមោះ*
*បុណ្យនឹងកើតកើន ចម្រើនឥតខ្ចោះ ត្រូវមានចិត្តស្មោះ*
*កុំលុបគុណខោល ។*

*កុំគ្រាន់តែថា មាតាបិតា មានគុណជាគោល*
*មាត់ថាត្រូវតប- គុណកុំច្បោលៗ ធ្វើដែរស្រាលៗ*
*សោះតែគេថា ។*

*ជនអ្នកតបគុណ ព្រះពុទ្ធមានបុណ្យ ទ្រង់ត្រាស់ទេសនា*
*សរសើរញឹកញយ មានក្នុងសាស្ត្រា គម្ពីរដីកា*
*គួរយើងចងចាំ ។*

*ចេះចាំហើយធ្វើ ដោយចិត្តអើពើ ឲ្យស៊ប់ឲ្យស៊ាំ*
*ឲ្យស្ថិទ្ធនឹងគុណ គុណតែងថែទាំ ពុំមែនខ្ចេចខ្ចាំ*
*ព្រោះតបគុណទេ ។*

ជនមានចិត្តខ្សោយ ច្រើនតែធ្វេសធ្លោយ រមិលគុណគេ
អាងព្រេងសំណាង ពីក្នុងបុព្វេ ប្រហេសធ្វេសទ្វេ
ព្រងើយកន្តើយ ។

អ្នកប្រាជ្ញប្រាប់ថា ជនប្រុសស្រីណា លុបគុណចោលហើយ
ជនប្រុសស្រីនោះ ពុំមានសុខស្បើយ យូរបុន្មានឡើយ
វែងតែធ្លាក់ខ្លួន ។

កំពុងមានសុខ ស្រាប់តែមានទុក្ខ ចេញមុខផ្លូនៗ
ឲ្យផលកំណាច ឃោរឃៅឥតស្លួន ទោសមកពីខ្លួន
រមឹលគុណគេ ។

ទេព្តាគេខឹង ព្រោះខ្លួនរឹងត្អឹង អាងបុណ្យបុព្វេ
ទោសបច្ចុប្បន្ន ជិះជាន់ឥតល្ហែ ភ័ព្វព្រេងបុព្វេ
បើមានក៏ផ្អាក ។

ទោសរមឹលគុណ រារាំងមុខបុណ្យ ព្រេងឲ្យសម្រាក
បង្អង់ឈប់សិន បាបថ្មីវិបាក ឲ្យផលឥតស្រាក
ព្រោះបានឱកាស ។

បុណ្យបាបចាស់ថ្មី តែងតែរំពៃ ពុំមែនផ្ដេសផ្ដាស
កាលមានចន្លោះ ត្រូវពេលសស្រាស ហាក់ដូចប្រកាស
ប្រាប់ថាត្រូវអញ ។

ចេញមុខផ្តល់ផល សុខទុក្ខឲ្យដល់ ជនដែលកកាញ់
កសាងបង្កើត កំណើតជាអញ អញជាសម្លាញ់
ត្រូវអញឲ្យផល ។

រីបុណ្យឬបាប ដែលមានសភាព ជាកម្មតែងផល
សុខទុក្ខឲ្យជន អ្នកធ្វើឲ្យដល់ នូវក្តីសល់រំលង
ឬក្តីសុខសាន្ត ។

បាបតែងរារាំង បុណ្យឲ្យនៅគាំង ផ្អាកសិនពុំបាន
ចេញមុខឲ្យផល ជាសុខសម្រាន្ត អ្នកធ្វើតែងបាន
ទទួលរងទុក្ខ ។

បុណ្យក៏រារាំង បាបឲ្យនៅគាំង ផ្អាកពុំចេញមុខ
ព្រោះមានឱកាស បុណ្យផ្តល់ក្តីសុខ សុទ្ធតែមានមុខ
ទីទៃពីគ្នា ។

ហេតុនោះគួរជន កុំនៅទម្រន់ ក្នុងក្តីខ្ជិលខ្ជា
គួរកសាងបុណ្យ មានគុណមហិមា ទើបបានឈ្មោះថា
អ្នកស្រឡាញ់ខ្លួន ។

សង្ខេបសេចក្តី សូមជនប្រុសស្រី បានសុខផូនៗ
ប្រាសចាកទុក្ខសោក រោគាក្នុងខ្លួន សតិមាំមួន
ចំរើនតទៅ ៕

# ខន្ធ ៥ ជាទុក្ខ

*(បទពាក្យ ៧)*

**កោ នុ ហាសោ កិមានន្ទោ   និច្ចំ បជ្ជលិតេ សតិ**

**អន្ធការេន ឱនទ្ធា បទីបំ   ន គវេសថ ។ល។**

*គួរអើរីករាយសើចក្អាកក្អាយ   លោកគឺរូបកាយកំពុងឆេះ*

*ងងឹតអន្ធការក្លាខ្លាំងម្ល៉េះ   គួរស្វែងចំណេះ បទីបា ។*

*ឃើញទេខន្ធ ៥ ប្រជុំចុះ   ចម្រុះដោយទុក្ខច្រើនប្រការ*

*ឈឺចាប់ព្រួយពិះច្រើនយ៉ាងណា   មិននៅបានការយូរប៉ុន្មាន ។*

*រូបនេះទ្រុឌទ្រោមប្រាកដជាក់   ពំនាក់នៃរោគគ្រប់សណ្ឋាន*

*បែកធ្លាយគួរខ្ពើមពន់ប្រមាណ   ជីវិតត្រូវបានស្លាប់ផុតជាក់ ។*

*ឆ្អឹងទាំងឡាយនេះចោលដេរដាស   ដូចឃ្លោកពោរពាស នាសារទ:*

*ឃើញឆ្អឹងពណ៌សដូចព្រាបជាក់   គួរអើចិត្តអ្នកត្រេកអរបាន ។*

*សង្ខារតាក់តែងនគរកាយ គ្រោង   ឆ្អឹងទាំងឡាយដូចផ្ទោងផ្ទាន*

*លាបដោយសាច់ឈាមបំភ័ន្តដាន   ចាស់ស្លាប់លុបគុណប្រកាន់ន័យ។*

*រថល្អដែលជាងសាងរចនា   គង់តែគ្រាំគ្រាខុសប្រក្រតី*

*ឯរូបរាងកាយជនប្រុសស្រី   គ្រប់វ័យជរាចូលបៀតបៀន ។*

*ចំណែកឯធម៌នៃសប្បុរស   ឋិតអស់កប្បក័ល្បមិនប្រែថ្កាន*

*សប្បុរសប្រឹក្សាផ្តល់សុខសាន្ត   ឲ្យបានសប្បុរសផងគ្នាយល់ ៕*